# សកម្មជនរំឭកឃាតកម្មលោក ជា វិជ្ជា ហើយស្នើឱ្យអាជ្ញាធររកឃាតករដើម្បីបញ្ចប់និទណ្ឌភាព។




រូបឯកសារ៖ សហាជីពម្នាក់កាន់ធូបនៅពីលើរូបថតរបស់លោក ជា វិជ្ជា ដែលជាអតីតប្រធានសហជីពសេរីកម្មករ ក្នុងអំឡុងពិធីគម្រប់ខួប ៦ ឆ្នាំនៃការសម្លាប់លោក ជា វិជ្ជា នៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមករា ឆ្នាំ ២០១០។

ចែករំលែក

សកម្មជនមួយចំនួននៅរំឭកដល់ការស្លាប់មេដឹកនាំសហជីពលេចធ្លោមួយរូបគឺលោក ជា វិជ្ជា ដែលត្រូវបានខ្មាន់កាំភ្លើងបាញ់ស្លាប់នៅកណ្ដាលទីក្រុងភ្នំពេញកាលពី១៩ឆ្នាំមុន។

លោក ជា វិជ្ជា អតីតប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានគេបាញ់ចំសៀតផ្កា និងដើមទ្រូង ដេកស្លាប់ក្នុងថ្លុកឈាម នាព្រឹកថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤ ខណៈលោកកំពុងឈរនៅក្នុងតូបកាសែតមួយ ខាងលិចវត្តលង្កា ក្នុងទីក្រុងភ្នំពេញ។

នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អ្នកស្រី ចក់ សុភាព ប្រាប់វីអូអេនៅថ្ងៃចន្ទនេះថា មិនទាន់ឃើញពន្លឺយុត្តិធម៌នៅឡើយចំពោះឃាតកម្មលើលោក ជា វិជ្ជា ដែលមិនខុសពីឃាតកម្មលើអ្នកអត្ថាធិប្បាយនយោបាយលោក កែម ឡី និងសកម្មជនការពារព្រៃឈើលោក ឈុត វុទ្ធី ។ អ្នកស្រី បន្ថែមថា ការណ៍នេះបានបង្កឲ្យមានវប្បធម៌និទណ្ឌភាព ឬភាពគ្មានទោសពៃរ៍នៅប្រទេសកម្ពុជា។

អ្នកស្រីថ្លែងថា៖ «យើងឃើញថា យុត្តិធម៌សម្រាប់ដូចជាលោក ជា វិជ្ជា ករណី លោក បណ្ឌិត កែម ឡី និងលោក ឈុត វុទ្ធី ដូចជានៅឆ្ងាយ ដែលនេះជាការបន្តនូវវប្បធម៌និទណ្ឌភាពនៅក្នុងសង្គមខ្មែរយើងហ្នឹង»។

បើតាមនាយិការូបនេះ វប្បធម៌និទណ្ឌភាព អាចបង្កការគំរាមកំហែងដល់សាធារណជន និងបំបាក់ស្មារតីប្រជាជពលរដ្ឋក្នុងសកម្មភាពតស៊ូមតិ។

អ្នកស្រីបញ្ជាក់ថា៖ «អ៊ីចឹងក្នុងនាមជាថ្នាក់ដឹកនាំរដ្ឋាភិបាលហ្នឹងគួរតែធ្វើកិច្ចការងារចាំបាច់ដើម្បីលុបបំបាត់នូវវប្បធម៌និទណ្ឌភាពនេះដើម្បីបញ្ជាក់ថា ប្រទេសកម្ពុជាយើងពិតជាមានប្រព័ន្ធនីតិរដ្ឋមួយដែលរឹងមាំ ហើយផ្ដល់យុត្តិធម៌ដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូបដោយមិនមានការរើសអើង»។

អ្នកស្រីបន្ថែមថា អាជ្ញាធរគួរប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួនក្នុងការស្វែងរកជនបង្កមកផ្ដន្ទាទោស ដើម្បីជាការផ្ដល់យុត្តិធម៌ដល់ជនរងគ្រោះ និងក្រុមគ្រួសារ។ ម្យ៉ាងវិញទៀត អាជ្ញាធរ

ត្រូវធានាសិទ្ធិក្នុងការដឹងឮរឿងរ៉ាវពិត កិច្ចគាំពារសង្គមសម្រាប់ប្រជាពលរដ្ឋឲ្យបានគ្រប់គ្រាន់ និងត្រូវធានាអំពីគោលការណ៍នីតិរដ្ឋ ដើម្បីកុំឱ្យប្រជាពលរដ្ឋបាត់បង់សេចក្ដីទុកចិត្តលើរដ្ឋាភិបាល។

ថ្លែងនៅក្នុងពិធីដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធនៅទីតម្កល់រូបសំណាកលោក ជា វិជ្ជា ខាងមុខវត្តលង្កា កាលពីថ្ងៃអាទិត្យ លោក វន់ ៣៧ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធបានអំពាវនាវឲ្យរដ្ឋាភិបាល ត្រូវតែបន្តនូវសកម្មភាពដើម្បីទាមទាររកយុត្តិធម៌សម្រាប់សកម្មជនសហជីព ដែលបានបាត់បង់ជីវិតក្នុងបុព្វហេតុការពារប្រយោជន៍កម្មករ និងសង្គមជាតិ។

លោកថ្លែងថា៖ «ខ្ញុំសូមយកឱកាសនេះអំពាវនាវម្ដងទៀតទៅដល់រាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធសូមរកឃាតករពិតដើម្បីផ្ដល់យុត្តិធម៌សម្រាប់យើងទាំងអស់គ្នា ដែលជាសិស្សរបស់លោក ជា វិជ្ជា ផ្ដល់យុត្តិធម៌ដល់ក្រុមគ្រួសាររបស់គាត់ ឲ្យយើងទុកចិត្តថា ឃាតករពិតជានរណា។ យើងមិនទាន់អស់ចិត្តនៅឡើយទេ»។

គួររំឭកថា ការបាញ់សម្លាប់លោក ជា វិជ្ជា កើតមានឡើង បន្ទាប់ពីលោកបានទទួលរងការព្រមានសម្លាប់ និងការគំរាមកំហែងពីជនមិនស្គាល់មុខជាបន្តបន្ទាប់ ចំពោះសកម្មភាពសហជីពដ៏សកម្មរបស់លោក ដើម្បីទាមទារអត្ថប្រយោជន៍ដល់កម្មកររួមមានទាំងការទាមទារដំឡើងប្រាក់ឈ្នួលផងដែរ។

អ្នកនាំពាក្យក្រសួងយុត្តិធម៌ លោក ជិន ម៉ាលីន ប្រាប់វីអូអេតាមប្រព័ន្ធទំនាក់ទំនងតេឡេក្រាមនៅថ្ងៃចន្ទនេះថា សមត្ថកិច្ចនៅតែបន្តស៊ើបអង្កេត និងស្រាវជ្រាវទៅលើករណីការស្លាប់របស់លោក ជា វិជ្ជា ហើយថា អាជ្ញាធរអាចត្រូវការពេលវេលាច្រើនក្នុងការបំបែកសំណុំរឿងស្មុគស្មាញ។

លោកថ្លែងថា៖ «ប្រព័ន្ធយុត្តិធម៌ឬមួយក៏សមត្ថភាពរបស់សមត្ថកិច្ចយើង បើប្រៀបធៀបជាមួយបណ្ដាប្រទេសគេផ្សេងទៀតក៏វាមិនជាអន់អីជាងគេប៉ុន្មានដែរក្នុងការស្រាវជ្រាវបំបែកសំណុំរឿង ព្រោះអីសំណុំរឿងស្មុគស្មាញនៅប្រទេសគេក៏គេចំណាយពេលច្រើនឆ្នាំរាប់ឆ្នាំ។

សំណុំរឿងខ្លះបំបែកបាន សំណុំរឿងខ្លះក៏បំបែកមិនបានដូចតែគ្នាអ៊ីចឹងដែរ ប៉ុន្តែគ្រាន់តែថា ក្នុងដំណើរការស្វែងរកយុត្តិធម៌គឺសមត្ថកិច្ចនៅតែបន្តធ្វើការងារហ្នឹង»។

ករណីលោក ជា វិជ្ជា ត្រូវបានក្រុមឃ្លាំមើលសិទ្ធិមនុស្សមើលឃើញថា ស្ថិតក្នុងចំណោម សំណុំរឿងដែលមិនទាន់ដោះស្រាយបានចប់សព្វគ្រប់ផ្សេងទៀត ដូចយ៉ាងករណីឃាតកម្ម លើនាដការី ពិសិដ្ឋ ពិលិកា នៅឆ្នាំ១៩៩៩ និងព្រះតេជព្រះគុណ សំ ប៊ុនធឿន នៅឆ្នាំ២០០៣ ជាដើម៕